# ស្ថានភាពសិល្បករ និងប្រព័ន្ធគាំពារសង្គម

ការស្រាវជ្រាវ «ឧស្សាហកម្មវប្បធម៌ និងច្នៃប្រតិដ្ឋក្រៅប្រព័ន្ធនៅកម្ពុជា៖ ការកំណត់ធនធានមនុស្ស និងស្ថានភាពសេដ្ឋកិច្ចសង្គម» បានផ្តល់អនុសាសន៍សំខាន់ៗចំនួន ៦ ដល់ភាគីពាក់ព័ន្ធ ក្នុងការទាញយកនូវធាតុចូលដល់ការសម្រេចចិត្តនានា ដើម្បីលើកកម្ពស់ស្ថានភាពសេដ្ឋកិច្ចសង្គមដល់សិល្បករ។ ក្នុងចំណោមចំណុចទាំង ៦ ក្នុងអត្ថបទ ស៊ីកាដាសូមលើកយកអនុសាសន៍តែមួយប៉ុណ្ណោះ ដូចខាងក្រោម ៖

> ការស្ទង់មតិបានរកឃើញថា សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ បានរួមចំណែកក្នុងសេដ្ឋកិច្ចកម្ពុជា តាមរយៈលទ្ធភាពនៃការរកចំណូលទ្រទ្រង់សម្រាប់មនុស្សម្នាក់ៗ។ ទោះបីជាយ៉ាងណាក៏ដោយ សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ទាំងនេះ មិនទទួលបានជំនួយគាំទ្រដោយគម្រោងគាំពារសង្គម ដូចជា ប័ណ្ណសមធម៌និងប័ណ្ណក្រីក្រនោះទេ ទោះបីជាពួកគាត់បានខិតខំប្រឹងប្រែងថែរក្សា និងអភិរក្សប្រពៃណី និងវប្បធម៌ដែលមិនអាចកាត់ថ្លៃបាននេះក៏ដោយ។ គួរតែមានគម្រោងគាំពារសង្គម និងធានារ៉ាប់រងសម្រាប់សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ ជាពិសេសអ្នកដែលធ្វើការខាងផ្នែកតន្ត្រី និងសិល្បៈទស្សនីយភាព ដែលតែងតែធ្វើដំណើរទៅសម្តែងនៅតាមកន្លែងផ្សេងៗឆ្ងាយពីសហគមន៍របស់ខ្លួន។

តាមរយៈអនុសាសន៍នេះ គេអាចយល់ថា បើទោះបីជាសិល្បករក្រៅប្រព័ន្ធបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការថែរក្សាសិល្បៈ វប្បធម៌កម្ពុជា និងរួមចំណែកក្នុងសេដ្ឋកិច្ចក៏ដោយ សិល្បករក្រៅប្រព័ន្ធមិនទទួលបានជំនួយគាំទ្រពីអត្ថប្រយោជន៍គាំពារសង្គមគ្រប់គ្រាន់នៅឡើយទេ។ អនុសាសន៍នេះបានស្នើឱ្យមានការគិតគូរដល់សិល្បករ និងអ្នកធ្វើការក្នុងវិស័យវប្បធម៌ ដើម្បីពួកគេបានទទួលអត្ថប្រយោជន៍គាំពារសង្គម ដូចប្រតិបត្តិករក្នុងវិស័យផ្សេងៗទៀត។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ រាជរដ្ឋាភិបាលបានយកចិត្តទុកបង្កើត និងពង្រីកវិសាលភាពនៃរបបសន្តិសុខសង្គមជាដំណាក់កាលបន្តបន្ទាប់ប្រកបដោយប្រសិទ្ធិភាពខ្ពស់គួរជាទីសាទរ។ តាមរយៈគេហទំព័រ «បេឡាជាតិសន្តិសុខសង្គម» បានសរសេរថា៖ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) មានភារកិច្ចផ្តល់នូវសន្តិសុខសង្គមជាមូលដ្ឋានជូនកម្មករនិយោជិតទាំងអស់ដែលធ្វើការក្នុងវិស័យឯកជន។ ប.ស.សចុះបញ្ជិកាសមាជិក ទទួលភាគទានរបស់សមាជិកនោះ គ្រប់គ្រងមូលនិធិនៃរបប ដំណើរការ និងផ្តល់តាវកាលិកដល់សមាជិក ឬអ្នកនៅក្នុងបន្ទុក។

បន្ថែមជាងនេះទៀត ថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជាបានចេញសេចក្តីប្រកាសព័ត៌មានមួយស្តីពី ការផ្តល់របបថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សម្រាប់បុគ្គលបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលមានគោលបំណងធានាឱ្យបាននូវសន្តិសុខប្រាក់ចំណូល កាត់បន្ថយភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច និងភាពក្រីក្ររបស់ប្រជាពលរដ្ឋ ក្រោមគោលការណ៍ «មិនចោលនរណាម្នាក់»។

សិល្បករ និងប្រតិបត្តករវប្បធម៌ជាភ្នាក់ងារដ៏សំខាន់សម្រាប់វិស័យទេសចរណ៍ ដូចនេះពួកគេគួរតែទទួលបាននូវអត្ថប្រយោជន៍នៃរបបគាំពារសង្គមពីរដ្ឋាភិបាលដូចប្រជាពលរដ្ឋក្រៅប្រព័ន្ធដទៃទៀតដែរ។ តែទោះជាយ៉ាងណា ជាការចាំបាច់ណាស់ ដែលត្រូវឈ្វេងយល់បន្ថែមអំពីប្រភេទនានានៃប័ណ្ណ ប.ស.ស អត្ថប្រយោជន៍នានា និងវិសាលភាពនៃប័ណ្ណ។ ដូចនេះ សូមអានលម្អិតនៃតារាងសង្ខេបខាងក្រោម៖

| ប្រភេទប័ណ្ណ | ប្រភេទអ្នកទទួលផលប្រយោជន៍ | លក្ខណៈសម្គាល់ប័ណ្ណ | លក្ខខណ្ឌ | វិសាលភាព |
|---|---|---|---|---|
| ប័ណ្ណសមាជិក<br>ប.ស.ស | មន្ត្រីរាជការសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន | ពណ៌ផ្ទៃមេឃ និងមានលេខសម្គាល់នៅចុងបំផុតនៃលេខសម្គាល់<br>8 ឧ. xxxxxxx. 8 | បង់ភាគទានប្រចាំខែ ជាបន្ទុករបស់រាជរដ្ឋាភិបាល | ១. ហានិភ័យការងារ (គ្រោះថ្នាក់ពេលបំពេញការងារ)<br>២. ថែទាំសុខភាព |
| ប័ណ្ណសមាជិក<br>ប.ស.ស | កម្មករក្នុងប្រព័ន្ធ (ធ្វើការក្នុងរោងចក្រ ក្រុមហ៊ុន ជាដើម មានប្រាក់ខែជាប្រចាំ...) | ពណ៌ផ្ទៃមេឃ និងមានអក្សរជាកំណត់សម្គាល់ នៅចុងបំផុតនៃលេខសម្គាល់។<br>ឧ.xxxxxxx. ប | បង់ភាគទានប្រចាំខែ<br>១. ភាគទានហានិភ័យការងារ និងថែទាំសុខភាព ជាបន្ទុកនិយោជកទាំងស្រុង<br>២. ភាគទានប្រាក់សោធន ជាចំណែករួមគ្នារវាងនិយោជក និងកម្មករនិយោជិត | ១. ហានិភ័យការងារ (គ្រោះថ្នាក់ពេលបំពេញការងារ)<br>២. ថែទាំសុខភាព<br>៣. ប្រាក់សោធន (ប្រាក់ពេលចូលនិវត្តន៍) |
| ប័ណ្ណសមាជិក<br>ប.ស.សសម្រាប់បុគ្គលស្វ័យនិយោជន៍ | អ្នកធ្វើការក្រៅប្រព័ន្ធ (អ្នកធ្វើការនៅសេវាកម្សាន្ត, អ្នករត់ម៉ូតូ/កង់បី, សិល្បករ/អ្នកធ្វើការក្នុងវិស័យវប្បធម៌ក្រៅប្រព័ន្ធ) អាចធ្វើបាន | ពណ៌ផ្ទៃមេឃ និងមានលេខសម្គាល់នៅចុងបំផុតនៃលេខសម្គាល់<br>7 ឧ. xxxxxxx. 7 | បង់ភាគទានតាមការស្ម័គ្រចិត្តចំនួន ១៥.៦០០ រៀល | ថែទាំសុខភាព<br>*(នាពេលអនាគត អាចទទួលបានប្រាក់សោធន)* |
| ប័ណ្ណមូលនិធិសមធម៌សុខាភិបាល | អ្នកធ្វើការក្រៅប្រព័ន្ធ (អ្នកធ្វើការនៅសេវាកម្សាន្ត, អង្គការសមាគម សិល្បករ/អ្នកធ្វើការក្នុងវិស័យវប្បធម៌ក្រៅប្រព័ន្ធ) | កាតពណ៌លឿង<br>សុពលភាពរយៈពេល១ឆ្នាំម្តង | មិនតម្រូវឱ្យបង់ប្រាក់<br>ជាបន្ទុករបស់រាជរដ្ឋាភិបាល | ថែទាំសុខភាព |

ដូចនេះ សង្ខេបជារួម សម្រាប់សិល្បករ/អ្នកធ្វើការក្នុងវិស័យវប្បធម៌ (អ្នកដំឡើងឆាក អ្នកច្នៃសម្លៀកបំពាក់សម្រាប់សិល្បករ អ្នកបោះពុម្ព អ្នករៀបចំមហោស្រព...) អាចមានសិទ្ធិទទួលបានប័ណ្ណមូលនិធិសមធម៌សុខាភិបាលដោយមិនចាំបាច់បង់ភាគទាន តែទទួលបានតែសេវាថែទាំសុខាភិបាលប៉ុណ្ណោះ។

ដើម្បីទទួលប័ណ្ណសមាជិក ប.ស.ស. បងប្អូនប្រជាពលរដ្ឋក្រៅក្របខណ្ឌ (អ្នកលក់ដូរ អ្នករត់ម៉ូតូ ឬកង់បី សិល្បករប្រចាំភូមិ ឃុំ ស្រុក...) លោកអ្នកត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម៖

👉បង់ភាគទានដោយស្ម័គ្រចិត្តចំនួន ១៥,៦០០ រៀលប៉ុណ្ណោះក្នុងមួយខែ

👉មានមុខរបរមានប្រាក់ចំណូលផ្ទាល់ខ្លួន មិនពាក់ព័ន្ធនឹងប្រាក់ឈ្នួល

👉ធ្វើការងារ ឬប្រកបរបរអាជីវកម្មផ្ទាល់ខ្លួន ដោយមិនប្រើប្រាស់បុគ្គលិក

👉ត្រូវមានអាយុមិនលើសពី៦០ឆ្នាំ គិតត្រឹមកាលបរិច្ឆេទស្នើចុះបញ្ជីនៅ ប.ស.ស.
👉សាមីខ្លួនត្រូវអញ្ជើញមកស្នើសុំធ្វើប័ណ្ណ ប.ស.ស. ដោយផ្ទាល់ និងភ្ជាប់ជាមួយនូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរច្បាប់ដើម (មានសុពលភាព)។
👉សម្រាប់ព័ត៌មានបន្ថែម សូមអញ្ជើញមកទីស្នាក់ការ ប.ស.ស. ដែលនៅជិតលោកអ្នកទូទាំងប្រទេស ឬទំនាក់ទំនងមកកាន់លេខ *១២៨៦* ឬតាមរយៈប្រព័ន្ធផ្សព្វផ្សាយបណ្ដាញសង្គមរបស់យើង។

(លក្ខខណ្ឌផ្សេងៗត្រូវបានអនុវត្ត)







(រូបភាព៖ ទំព័រហ្វេកប៊ុកផ្លូវការនៃបេឡាជាតិសន្តិសុខសង្គម)

សូមបញ្ជាក់ថា សិល្បករ/ប្រតិបត្តិករក្រៅប្រព័ន្ធអាចចុះឈ្មោះ ដើម្បីដាក់ពាក្យស្នើប័ណ្ណសមធម៌តាមរយៈសមាគមសីុកាដាក៏បាន ដើម្បីសមាគមអាចដាក់ពាក្យស្នើសុំជំនួសលោកអ្នកបាន។ ដើម្បីធ្វើដូច្នេះបាន លោកអ្នកតម្រូវឱ្យចុះឈ្មោះជាសមាជិកសមាគមសីុកាដាជាមុនសិន។ សមាគមសីុកាដានឹងព្យាយាមឱ្យអស់ពីលទ្ធភាព ដើម្បីស្នើសុំប័ណ្ណនេះសម្រាប់សមាជិករបស់ខ្លួន។ តែទោះជាយ៉ាងណា សិទ្ធិសម្រេចផ្ដល់ប័ណ្ណមូលនិធិសមធម៌សុខាភិបាលជាការសម្រេចចិត្តរបស់បេឡាជាតិសន្តិសុខសង្គម។ សម្រាប់ព័ត៌មានអំពីសមាគមសីុកាដា សូមទាក់ទងមកតេឡេក្រាម 012 432 201។

សម្រាប់ទំនាក់ទំនង និងទីស្នាក់ការ ប.ស.ស នៅទូទាំងប្រទេស សូមអានគេហទំព័រ http://www.nssf.gov.kh ឬតាមដានតាម Telegram: Contact @nssfcambodia_Chat